# តារាងស្តីពីព័ត៌មានរបស់គម្រោង

លេខPIP : 633

(សម្រាប់បំពេញដោយក្រសួងផែនការ)

## ព័ត៌មានមូលដ្ឋានអំពីគម្រោង

ផ្នែក ក

*(ត្រូវបំពេញគ្រប់ចំណុចទាំងអស់)*

១. ឈ្មោះគម្រោង : ការធ្វើឱ្យប្រសើរឡើងនូវខ្សែច្រវាក់តម្លៃកៅស៊ូធម្មជាតិ

២. កាលបរិច្ឆេទគម្រោង

| | |
|---|---|
| កាលបរិច្ឆេទចាប់ផ្តើមគម្រោង | 01/01/26 |
| កាលបរិច្ឆេទបញ្ចប់គម្រោង | 31/12/30 |

៣. ចំណាយគម្រោងសរុប $13,500,000

៤. ស្ថាប័នទទួលខុសត្រូវ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

| | |
|---|---|
| RESPONSIBLE UNIT | GDR |
| អង្គភាពទទួលខុសត្រូវ | អគ្គនាយកដ្ឋានកៅស៊ូ |

៥. ស្ថានភាពគម្រោង គម្រោងសម្រាប់អនុវត្តផ.យ.អ.ជ.

ព័ត៌មានលម្អិតអំពីគម្រោង

៦. ប្រភេទគម្រោង ៖ គម្រោងវិនិយោគជាទុន

៧. ប្រភពហិរញ្ញប្បទាន៖ ស្វែងរកម្ចាស់ជំនួយ

៨. មុំនៃគោលនយោបាយក្នុងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ដែលគម្រោងស្ថិតនៅ

មុំទី៣- ការលើកស្ទួយកសិកម្ម និងការអភិវឌ្ឍជនបទ

៩. ការចូលរួមចំណែករបស់គម្រោងក្នុងការសម្រេចបានគោលនយោបាយអាទិភាពខាងលើ

គម្រោងនេះ បានចូលរួមចំណែកក្នុងគោលនយោបាយជាតិអភិវឌ្ឍន៍វិស័យកសិកម្ម ២០២២-២០៣០ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កៅស៊ូធម្មជាតិឆ្ពោះទៅឆ្នាំ២០៣០។

### ១០. ការគាំទ្រដល់គោលនយោបាយអភិវឌ្ឍន៍ វិស័យឧស្សាហកម្មកម្ពុជា

តើគម្រោងនេះគាំទ្រដល់ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាដែរឬទេ ? គាំទ្រ

ការកែលម្អបរិស្ថាននិយ័តកម្ម (វិធានការសម្រួលពាណិជ្ជកម្ម និងជំរុញការនាំចេញ ការពង្រឹងបទដ្ឋានឧស្សាហកម្មនិងកម្មសិទ្ធិឧស្សាហកម្ម ការសម្រួលការបំពេញកាតព្វកិច្ចពន្ធនិងអាករ និងការរៀបចំទីផ្សារពលកម្មនិងទំនាក់ទំនងវិជ្ជាជីវៈ)

១១. វិស័យ ( សូមជ្រើសរើស អនុវិស័យ ដែលមានចែងក្នុងផ.យ.អ.ជ. )

កសិកម្ម និងការគ្រប់គ្រងដីធ្លី

**១២. ទីតាំងអនុវត្តគម្រោង** ( ពិពណ៌នាពីទីតាំងដែលត្រូវអនុវត្តគម្រោង )

**ប៉ៃលិន, ត្បូងឃ្មុំ , រតនគិរី, ព្រះវិហារ, កំពង់ធំ, បាត់ដំបង, មណ្ឌលគិរី,**

**១៣. គោលបំណងរបស់គម្រោង** ( ពិពណ៌នាគោលបំណងចម្បងៗរបស់គម្រោង )

**បង្កើនផលចំណេញដល់ប្រតិបត្តិករកៅស៊ូ ដើម្បីលើកកម្ពស់ជីវភាពពួកគាត់ ក៏ដូចសេដ្ឋកិច្ចសង្គម។**

**១៤. ការពិពណ៌នាអំពីគម្រោង** ( ពិពណ៌នាអំពីសមាសភាគទាំងអស់របស់គម្រោង )

ដើម្បីសម្រេចនូវគោលដៅ គម្រោងបានរៀបចំនូវសកម្មភាពសំខាន់ៗ ដូចខាងក្រោម៖

1. កាត់បន្ថយថ្លៃដើម

• ការបណ្តុះបណ្តាលបច្ចេកទេសយកផលទឹកជ័រនិងប្រើប្រាស់ជាតុចូលសមស្រប (ប្រព័ន្ធចៀរអាំងតង់ស៊ីតេទាប រំញោចកម្ម ការគ្រប់គ្រងផ្ទាំងចៀរ) ដែលធន់ទ្រាំនឹងការប្រែប្រួលអាកាសធាតុដល់កសិករកៅស៊ូគ្រួសារ

• ការបង្កើតទីតាំងចម្ការកៅស៊ូបង្ហាញ (Rubber Demonstration plantation) ពីអនុវត្តកសិកម្មល្អលើការយកផលទឹកជ័រ

• រៀបចំទស្សនកិច្ចសិក្សារបស់កសិករកៅស៊ូគ្រួសារ

• បង្កើតអនុស្ថានីយឧតុនិយមនៅតាមតំបន់។

2. បង្កើនតម្លៃបន្ថែមនិងបង្កើតការងារ

• ការសិក្សាសមិទ្ធិលទ្ធភាពបង្កើតមណ្ឌលកែច្នៃ

• ការបង្កើតក្រុមកែច្នៃរបស់កសិករកៅស៊ូគ្រួសារ

• ការកសាងសមត្ថភាពអំពីការកែច្នៃកៅស៊ូ

• ការផ្តល់ជំនួយបច្ចេកទេស និងការសម្របសម្រួលការងារគ្រប់គ្រង

• ការផ្តល់កម្ចីការសាងសង់មណ្ឌលកែច្នៃកៅស៊ូសន្លឹកសំងិលដោយខ្យល់ (USS) ចំនួន២០កន្លែង

• ការផ្តល់កម្ចីការការសាងសង់មជ្ឈមណ្ឌលកែច្នៃកៅស៊ូសន្លឹកសម្ងួតដោយមានផ្សែង (RSS) ចំនួន០៥កន្លែង

3. បង្កើនអាយុសេដ្ឋកិច្ចដើមកៅស៊ូ

• ការបណ្តុះបណ្តាលបច្ចេកទេសត្រួតពិនិត្យគុណភាពចៀរជ័រ

• ការចុះពិនិត្យស្ថានភាពជាក់ស្តែងនិងផ្តល់ប្រឹក្សាបច្ចេកទេសនៅចម្ការកៅស៊ូ

4. ពង្រីកនិងពង្រឹងទីផ្សារ

• ការសិក្សាសមិទ្ធិលទ្ធភាពបង្កើតមជ្ឈមណ្ឌលទីផ្សារកៅស៊ូ

• ការសាងសង់មណ្ឌលទីផ្សារកៅស៊ូ

• ការកសាងសមត្ថភាពអំពីដំណើរការទីផ្សារ

• ជំរុញការប្រើប្រាស់កៅស៊ូក្នុងស្រុក

• ជំរុញការនាំចេញទៅការទីផ្សារមានសក្តានុពល

5. គ្រប់គ្រងនិងផ្តល់ព័ត៌មានកៅស៊ូតាមប្រពន្ធ័អេឡិចត្រូនិកឱ្យបានល្អនិងទាន់ពេល

• ការប្រមូលព័ត៌មាន ការគ្រប់គ្រង និងការធ្វើបច្ចុប្បន្នភាពប្រព័ន្ធស្ថិតិ

• កាបង្កើតប្រព័ន្ធគ្រប់គ្រងនិងតាមដានព័ត៌មានកៅស៊ូធម្មជាតិ ដោយប្រើប្រាស់កម្មវិធីGIS កម្មវិធីតាមបច្ចេកវិទ្យាគមនាគមន៍ព័ត៌មានICT កសាងRubber Logistic និងកម្មវិធីផ្សេងៗទៀត

• កសាងសមត្ថភាពមន្ត្រីក្នុងការប្រមូល គ្រប់គ្រង និងប្រើប្រាស់ទិន្នន័យកៅស៊ូ

• ការស្រង់ស្ថិតិកៅស៊ូធម្មជាតិ

• បង្កើតផែនទី នៃចំការកៅស៊ូគ្រួសារនៅទូទាំងប្រទេស

• គ្រប់គ្រងទិន្នន័យស្ថិតិលើដីសមស្របសម្រាប់ការដាំដុះកៅស៊ូ និងផ្តល់សេវាបច្ចេកទេស ការបង្ការនិងព្យាបាលជំងឺ

6. ពង្រឹងការគ្រប់គ្រងនិងរចនាសម្ព័ន្ធ

• រៀបចំលិខិតគតិយុត្តនិងគោលនយោបាយអភិវឌ្ឍន៍សេដ្ឋកិច្ចកៅស៊ូ

១៥. យុត្តិកម្មលើគម្រោង (បង្ហាញពីហេតុផលថាហេតុអ្វីបានជាគម្រោងនេះត្រូវបានជ្រើសរើស)

កៅស៊ូធម្មជាតិ គឺជាដំណាំយុទ្ធសាស្ត្ររយៈពេលវែង និងបានផ្តល់ប្រយោជន៍សេដ្ឋកិច្ចជាច្រើនដល់អ្នកដាំ ដល់សេដ្ឋកិច្ចជាតិ ដល់សង្គម និងបរិស្ថាន ជាពិសេសបានចូលរួមកាត់បន្ថយភាពក្រីក្រ តាមរយៈការបង្កើតការងារ និងមុខរបរមានស្ថិរភាពនៅនឹងកន្លែង ជូនប្រជាពលរដ្ឋនៅតាមទីជនបទ បង្កើតជាគម្របបៃតងឡើងវិញ និងកាត់បន្ថយបម្រែបម្រួលអាកាសធាតុ ដែលជាបញ្ហាប្រឈម របស់ពិភពលោក នាពេលបច្ចុប្បន្ននិងទៅអនាគត។

រយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ផ្ទៃដីដំណាំកៅស៊ូធម្មជាតិនៅកម្ពុជាពុំមាននិន្នាការប្រែប្រួល ហើយស្ថិតក្នុងបរិមាណសរុប ក្នុងរង្វង់ប្រមាណ៤២៥ពាន់ហិកតា ក្នុងនោះកៅស៊ូគ្រួសារមានប្រមាណជា ៤៨% នៃផ្ទៃដីសរុបនេះ។

ថ្លៃលក់កៅស៊ូរបស់កសិករកៅស៊ូគ្រួសារនៅចម្ការបានត្រឹម៧០-៧៥%នៃថ្លៃទីផ្សារអន្តរជាតិ គឺទាបជាងនៅបណ្តាប្រទេសកៅស៊ូជិតខាង។ ជាមួយគ្នានេះ កម្ពុជា ក៏នៅ បន្តបាត់បង់ឱកាសក្នុងការបង្កើតតម្លៃបន្ថែម តាមរយៈការកែច្នៃកៅស៊ូទៅទៅជាផលិតផលកៅស៊ូកែច្នៃបឋម ( CSR, RSS, CL, Compounded Rubber ។ល។) មុនពេលធ្វើការនាំចេញ។

ឆ្លើយតបនឹងស្ថានភាពនេះ ការលើកគម្រោងស្តីពី ការធ្វើឱ្យប្រសើរឡើងនូវខ្សែច្រវាក់តម្លៃកៅស៊ូធម្មជាតិ ដើម្បីកំណត់ទិសដៅក្នុងការបង្កើនទិន្នផលកៅស៊ូ បន្ថយថ្លៃដើមផលិតកម្ម តាមរយៈការបណ្តុះបណ្តាលដោយផ្តោតលើជំនាញបច្ចេកទេសយកផលកៅស៊ូ ការពង្រឹងគុណភាពនិងពង្រីកទីផ្សារកៅស៊ូធម្មជាតិប្រកបដោយនិរន្តរភាព ជំរុញការកែច្នៃនិងប្រើប្រាស់ក្នុងស្រុក ដើម្បីបង្កើនផលចំណេញ គឺសុទ្ធសឹងតែជាការងារអាទិភាព។

**១៦. ផលប្រយោជន៍របស់គម្រោង** (រៀបរាប់ពីអ្នកដែលនឹងទទួលប្រយោជន៍ផ្ទាល់និងមិនផ្ទាល់ពីការអនុវត្តគម្រោង)

**អ្នកទទួលផលផ្ទាល់៖** សហគមន៍កសិកម្មកៅស៊ូគ្រួសារ និងកសិករកៅស៊ូគ្រួសារ ក្រុមហ៊ុនចម្ការកៅស៊ូកសិឧស្សាហកម្ម រោងចក្រ សិប្បកម្មកែច្នៃផលិតផលកៅស៊ូ និងមន្ត្រីរាជការក្នុងវិស័យកៅស៊ូ។

**១៧. ការសិក្សាសមិទ្ធិលទ្ធភាព**

| | |
|---|---|
| តើគម្រោងនេះតម្រូវឲ្យមានការសិក្សាសមិទ្ធិលទ្ធភាពដែរ ឬទេ? | **មាន** |
| ប្រសិនបើត្រូវការ តើការសិក្សាសមិទ្ធិលទ្ធភាព បានរៀបចំហើយឬនៅ? | **មិនទាន់ចាប់ផ្តើម** |

**១៨. ផលប៉ះពាល់ផ្នែកបរិស្ថាននិងសង្គម** (ពិពណ៌នាសង្ខេបពីផលប៉ះពាល់របស់គម្រោងលើប្រជាជននិងបរិស្ថានជុំវិញ ប្រសិនបើមាន។ តើគម្រោងនេះនឹងជួយដល់ការកាត់បន្ថយភាពក្រីក្រដែរឬទេ?)

គម្រោងនេះចូលរួមកាត់បន្ថយភាពក្រីក្រនៅជនបទនិងបង្កើនផលិតភាពកសិកម្ម

**១៩. ការប្រែប្រួល អាកាសធាតុ**

ក. តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ ទងនឹងការប្រែប្រួលអាកាសធាតុ ឬទេ? **គ្មាន**

ខ. តើគម្រោងមានភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុកម្រិតណា?

សូមជ្រើសរើសវិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងនិងបំពេញការចូលរួមចំណែកនៃចំណាយដែល ទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងធៀបនឹងតម្លៃគម្រោងសរុប។

| វិស័យដែលទាក់ទងនឹង ការប្រែប្រួលអាកាសធាតុ | ភាគរយ | ភាពទាក់ទងនឹងការប្រែប្រួល អាកាសធាតុ |
|---|---|---|
| **១៨. ជីវភាពរស់នៅ (ទូទៅ)** | 100 | **ទាក់ទងខ្លាំង** |

**២០. ការកាត់បន្ថយ ហានិភ័យ និង គ្រោះមហន្តរាយ**

តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ទងនឹងការកាត់បន្ថយហានិភ័យ និងគ្រោះមហន្តរាយដែរឬទេ? **គ្មាន**

**២១. ការវិភាគយេនឌ័រ** (តើគម្រោងនេះមានផលប៉ះពាល់ដល់តួនាទីរបស់បុរសនិងស្ត្រីក្នុងទីតាំងរបស់គម្រោងនេះដូចម្តេច? តើស្ត្រីនឹងត្រូវចូលរួមយ៉ាងសកម្មក្នុងការអនុវត្តគម្រោងនេះដែរឬទេ?)

**គម្រោងនេះនឹងគាំទ្រដល់តួនាទីរបស់បុរសនិងស្ត្រីក្នុងអនុវិស័យកៅស៊ូ ពិសេសលើកទឹកចិត្តដល់ការចូលរួមរបស់ស្ត្រី។**

**២២. សមត្ថភាពអនុវត្តគម្រោង** (តើក្រសួងមានជំនាញនិងបទពិសោធន៍គ្រប់គ្រាន់សម្រាប់អនុវត្តគម្រោងដែរឬទេ?)

**អគ្គនាយកដ្ឋានកៅស៊ូ មានសមត្ថភាពគ្រប់គ្រាន់ក្នុងការគ្រប់គ្រងគម្រោងនេះ។ ចំណែកបរិក្ខាបច្ចេកវិទ្យាធ្វើលទ្ធកម្ម និងសេវាកម្មទីប្រឹក្សាបច្ចេកទេសនឹងរកពីខាងក្រៅ។**

**២៣. ស្ថានភាពនៃការអនុវត្តគម្រោង** (ពិពណ៌នាសង្ខេបអំពីវឌ្ឍនភាពរបស់គម្រោងនិងបង្ហាញអំពីភាពប្រឈមនានា ដែល បណ្តាលឲ្យមាន ការពន្យាពេលក្នុងការអនុវត្តគម្រោង។)

**គម្រោងស្នើសុំជំនួយ។**

**២៤. អាទិភាពរបស់គម្រោង** (បញ្ជាក់ពីការកំណត់អាទិភាពរបស់គម្រោងរបស់ក្រសួង ស្ថាប័ន)

1

**២៥. ការចូលរួមរបស់ដៃគូអភិវឌ្ឍ** (ផ្តល់ព័ត៌មានអំពីដៃគូអភិវឌ្ឍសក្តានុពល ដែលពាក់ព័ន្ធនឹងគម្រោងនេះ)

**កំពុងស្វែងរកដៃគូអភិវឌ្ឍដើម្បីផ្តល់ជំនួយ។**

## ផ្នែក ខ ចំណាយរបស់គម្រោងនិងប្រភពហិរញ្ញប្បទាន

*(គិតជាពាន់ដុល្លារអាមេរិក)*

| ចំណាយវិនិយោគ | 2024 | | 2025 | 2026 | 2027 | 2028 | សរុប | ថវិកា |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2026-2028 | ចរន្ត |
| **ចំណាយប្រតិបត្តិ** | 0.0 | 0.0 | 0.0 | 1,435.2 | 384.6 | 276.9 | 2,096.7 | 0.0 |
| | | | | | | | | |
| បៀវត្សរ៍ | 0.0 | 0.0 | 0.0 | 166.4 | 189.4 | 189.4 | 545.2 | 0.0 |
| សម្ភារៈនិងរដ្ឋបាល | 0.0 | 0.0 | 0.0 | 1,265.8 | 46.5 | 51.8 | 1,364.1 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 3.0 | 148.7 | 35.7 | 187.4 | 0.0 |
| | | | | | | | | |
| **ចំណាយមូលធន** | 0.0 | 0.0 | 0.0 | 3,465.1 | 1,935.5 | 2,328.0 | 7,728.6 | 0.0 |
| | | | | | | | | |
| ការសាងសង់ | 0.0 | 0.0 | 0.0 | 1,227.0 | 838.8 | 1,128.2 | 3,194.0 | 0.0 |
| សេវាទីប្រឹក្សា | 0.0 | 0.0 | 0.0 | 82.5 | 82.5 | 82.5 | 247.5 | 0.0 |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ទព្វសម្ភារៈ | 0.0 | 0.0 | 0.0 | 1,725.8 | 445.9 | 523.8 | 2,695.5 | 0.0 |
| ការបណ្តុះបណ្តាល | 0.0 | 0.0 | 0.0 | 109.2 | 455.1 | 472.8 | 1,037.1 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 320.6 | 113.2 | 120.7 | 554.5 | 0.0 |
| | | | | | | | | |
| ចំណាយសរុប | 0.0 | 0.0 | 0.0 | 4,900.3 | 2,320.1 | 2,604.9 | 9,825.3 | 0.0 |
| | | | | | | | | |

| ប្រភពហិរញ្ញប្បទាន | 2024 | | 2025 | 2026 | 2027 | 2028 | សរុប | |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2026-2028 | |
| | | | | | | | | |
| ចំណូលពីគម្រោង | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| ថវិកាជាតិ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| សាច់ប្រាក់សុទ្ធ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| ធនធានផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| ហិរញ្ញប្បទាន របស់ ដៃគូអភិវឌ្ឍ | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| សរុបហិរញ្ញប្បទាន ដែលបានសន្យាផ្តល់ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| តម្រូវហិរញ្ញប្បទាន បំពេញបន្ថែម | 0.0 | 0.0 | 0.0 | 4,900.3 | 2,320.1 | 2,604.9 | 9,825.3 | |

**បានឃើញ និង ឯកភាព**

**រដ្ឋមន្ត្រី**

កាលបរិច្ឆេទ: